# ជីអំពុក

ភាសាខ្មែរ

## សំនួរនាំឲឡាយអំពីជីអំពុក

**១) សៈ ជីអំពុករបស់ខ្ញុំស្ងួតយ៉ាងខ្លាំង តើខ្ញុំត្រូវធ្វើដូចម្តេច?**

ចម្លើយៈ ដាក់បន្ថែមទឹក នៅពេលលោកអ្នកជ្រោយជីអំពុករបស់លោកអ្នក។ ដាក់បន្ថែមទឹករហូតទាល់តែជីអំពុកសើម ក៏ប៉ុន្តែកុំឲ្យវាសើមខ្លាំងពេក។ គ្របគំនរជីអំពុកដើម្បីកុំឲ្យវាស្ងួតលឿនពេក។

**២) សៈ ជីអំពុករបស់ខ្ញុំសើមយ៉ាងខ្លាំង តើខ្ញុំត្រូវធ្វើដូចម្តេច?**

ចម្លើយៈ ជ្រោយជីអំពុករបស់លោកអ្នក ក្នុងខណៈដែលដាក់បន្ថែមសារធាតុពណ៌ត្នោត។ ប្រសិនបើលោកអ្នកដាក់ជីអំពុកនៅក្នុងធុង ចូរយកសារធាតុពណ៌បៃតងចេញខ្លះ ហើយដាក់សារធាតុពណ៌ត្នោតចូលឲ្យបានច្រើន។





**៣) សៈ ហេតុអ្វីបានជាជីអំពុករបស់ខ្ញុំធំក្លិនអាក្រក់ខ្លាំងម្ល៉េះ?**

ចម្លើយៈ ជីអំពុករបស់លោកអ្នកមានទឹក និងសារធាតុពណ៌បៃតងច្រើនពេក។ ចូរជ្រោយជីអំពុកឲ្យបាន២ ឬ៣ដង ហើយដាក់បន្ថែមសារធាតុពណ៌ត្នោតខ្លះ។ ជ្រោយគំនរជីអំពុក២ដង ក្នុង១អាទិត្យ ឲ្យបានចំនួន១២អាទិត្យ។

**៤) សៈ ហេតុអ្វីបានជាជីអំពុករបស់ខ្ញុំមិនក្លាយទៅជាជីអំពុក?**

ចម្លើយៈ ជីអំពុករបស់លោកអ្នកមានសារធាតុពណ៌ត្នោតច្រើនហួសពេក។ ចូរយកសារធាតុពណ៌ត្នោតចេញខ្លះ ហើយដាក់បន្ថែមវិញនូវសារធាតុពណ៌បៃតងខ្លះ ស្រោចទឹក ហើយជ្រោយវា។ ជ្រោយ២ដង ក្នុង១អាទិត្យ ឲ្យបានចំនួន១២អាទិត្យ។

Hawkesbury Nepean Catchment Management Authority

ORTA RECENS QUAM PURA NITES

NSW DEPARTMENT OF PRIMARY INDUSTRIES

# ជីអំពុក

## ហេតុអ្វីបានជាត្រូវធ្វើជីអំពុក?



- ជីអំពុកជួយថែរក្សាដីឲ្យមានគុណភាពល្អ។.
- ជីអំពុកជំរុញឲ្យសារធាតុល្អៗរស់នៅក្នុងដី។
- ជីអំពុកជួយឲ្យរចនាសម្ព័ន្ធដីបានកាន់តែល្អប្រសើរឡើង។
- ជីអំពុកជួយឲ្យបន្លែដុះលូតលាស់បានល្អ។
- ជីអំពុកជួយការពាររុក្ខជាតិតូចតាចឥតប្រយោជន៍កុំឲ្យដុះ ធ្វើឲ្យបានទទួលពន្លឺថ្ងៃច្រើន មានទីលំហ មានជាតិទឹក ហើយជាសារធាតុដែលជួយធ្វើឲ្យដំណាំរបស់លោកអ្នកលូតលាស់បានល្អ។



- ជីអំពុកជួយជំរុញឲ្យមានសត្វក្នុងដីដែលមានប្រយោជន៍ ដូចជាជន្លេនដែលបន្ថែមឲ្យមានសារធាតុ ហើយជួយនាំខ្យល់ចូលទៅក្នុងដី។
- ជីអំពុកជួយឲ្យដីត្រសុះងាយស្រួលប្រើ។
- ជីអំពុកជួយផ្ទុកទឹកក្នុងដី ដូច្នេះលោកអ្នកពុំចាំបាច់បញ្ចូលទឹកច្រើនទេ។
- ជីអំពុកធ្វើឲ្យដីមានគុណភាពល្អ ហើយជួយឲ្យដំណាំដុះបានល្អ។

© NSW DPI February 2007

ដើម្បីទទួលយកព័ត៌មានបន្ថែមទៀតសូមទាក់ទង

Gosford Horticultural Institute
NSW Department of Primary Industries
Locked Bag 26 Gosford NSW 2250
ph: 02 4348 1913  fax: 02 4348 1910